ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

# ស្តីពី

# ការឃោសនាបោះឆ្នោតជ្រើសតាំង
# សមាជិកព្រឹទ្ធសភា នីតិកាលទី៤

(ថ្ងៃបោះឆ្នោត នៅថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨)

# អារម្ភកថា

សៀវភៅណែនាំស្តីពី ការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ត្រូវបានចងក្រងឡើងជាឯកសារសម្រាប់ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ ពិសេសគណបក្សនយោបាយទាំងអស់ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដើម្បីឱ្យងាយស្រួលយល់អំពីបទបញ្ញា និងនីតិវិធី ក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ សៀវភៅនេះជាជំនួយស្មារតីក្នុងការអនុវត្តសកម្មភាពឃោសនាបោះឆ្នោតផ្ទាល់ និងការអនុវត្តសកម្មភាពផ្សេងៗទៀតដែលទាក់ទងដល់ការឃោសនាបោះឆ្នោត ។

ខ្លឹមសារក្នុងសៀវភៅនេះត្រូវបានដកស្រង់ចេញពីបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ និងត្រូវបានបញ្ចូលនូវឧបសម្ព័ន្ធមួយចំនួនដែលជាសម្រង់មាត្រានៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រង់មាត្រានៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ទាក់ទងដល់ការឃោសនាបោះឆ្នោត និងគោលការណ៍មួយចំនួនដែលពាក់ព័ន្ធដល់ការឃោសនាបោះឆ្នោត ៕

# មាតិកា

ទំព័រ

អារម្ភកថា---------------------------------------------------- i

មាតិកា------------------------------------------------------ ii

អក្សរកាត់---------------------------------------------------- iv

១- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជំពូកទី ៦ ការឃោសនាបោះឆ្នោត

- បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត -------------------- ១
- សម្ភារអប់រំអ្នកបោះឆ្នោត------------------------------------ ២០
- រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ -------------------- ២៥
- ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន--------- ៣៨

២- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រង់ជំពូកទី ៧ ប្រការ ៧.៥ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ --------------------- ៤០

៣- ឧបសម្ព័ន្ធ

ក. សម្រង់ជំពូកទី ៥ ស្តីពីការឃោសនាបោះឆ្នោត នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ------------- ៤៦

ខ. សម្រង់មាត្រាមួយចំនួនក្នុងជំពូកទី ១០ ស្តីពីទោសប្បញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា -------------------------------------- ៤៨

គ. គោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយគណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត -------------------- ៥៦

ឃ. គោលការណ៍សម្រាប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយអំពីកម្មវិធីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងអំឡុងពេលឃោសនាបោះឆ្នោត ------------- ៦១

ង. គោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃកម្មវិធីផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ------- ៦៥

ច. គោលការណ៍សម្រាប់បោះពុម្ព និងផ្សព្វផ្សាយអត្ថបទឃោសនារបស់គណបក្សនយោបាយក្នុងព្រឹត្តិបត្រគោលនយោបាយគណបក្ស ------------------------------ ៦៨

ឆ. ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ ឆ្នាំ២០១៨ (វិសោធនកម្ម) ------------------- ៧២

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣. | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត | លគធ.ខប |
| ៤. | គណៈកម្មការការិយាល័យបោះឆ្នោត និង ការិយាល័យរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៥. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា | ច.ប.ព.ស |
| ៦. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| ៧. | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើស តាំងសមាជិកព្រឹទ្ធសភា | ប.ន.ព.ស |

# បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា

# ជំពូកទី ៦
# ការឃោសនាបោះឆ្នោត

## បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត

### ប្រការ ៦.១.-

អនុលោមតាម ច.ប.ព.ស និង ច.ប.ត.រ ការឃោសនាបោះឆ្នោតមានទិសដៅឱ្យបេក្ខជន និងគណបក្សនយោបាយដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។ ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។ សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ មានដូចជា ៖

៦.១.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

៦.១.២ ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅមណ្ឌលភូមិភាគនីមួយៗត្រូវកំណត់យ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

៦.១.៣ ការជួបជុំ ឬការឃោសនាតាមផ្ទះ ។

៦.១.៤ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។

៦.១.៥ ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាស្សែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីផ្លាសាធារណៈ។

៦.១.៦ សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា ។

៦.១.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ។

៦.១.៨ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួកសម្លៀកបំពាក់ សម្ភារផ្សេងៗទៀត ដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជនជូនអ្នកបោះឆ្នោត ។

៦.១.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទប្រកាសផ្សាយ ។

៦.១.១០ ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ។

៦.១.១១ ការរៀបចំកម្មវិធីប្រកួតកីឡា ។

**ប្រការ ៦.២..**

ការឃោសនាត្រូវបើករយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត។

៦.២.១ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវចាប់ផ្ដើមពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់) យប់ ។

៦.២.២ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ៦ (ប្រាំមួយ) ព្រឹក។

៦.២.៣ សកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍បំពងសំឡេងត្រូវបានកំណត់ ដូចខាងក្រោម ៖

- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២ (ពីរ) រសៀល ។
- ត្រូវហាមឃាត់នៅក្បែរមន្ទីរពេទ្យ ។
- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងពេលម៉ោងសិស្សកំពុងសិក្សា លើកលែងតែនៅក្រៅពេលម៉ោងសិក្សា ។

៦.២.៤ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោតត្រូវបញ្ឈប់ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃ

បោះឆ្នោត ។ ការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរ ដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីការបោះឆ្នោត ។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម ៖

- ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង
- រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ
- ការគោរពសិទ្ធិ សេរីភាពរបស់បុគ្គល
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត
- ការមិនបង្កឱ្យមានអសន្តិសុខ ភាពចលាចល ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឱ្យភាន់ច្រឡំក្នុងដំណើរការបោះឆ្នោត
- លទ្ធផលដែលបានមកពីការស្ទង់មតិ ត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព ។

៦.២.៥ គ្រប់សកម្មភាពឃោសនាបោះឆ្នោតដែលមានចែងក្នុងជំពូកទី ៦ នៃ ប.ន.ព.ស នេះ ត្រូវបញ្ឈប់ទាំងអស់ក្នុងអំឡុងពេល ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។ ជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះ នឹងត្រូវទទួលការពិន័យតាម ច.ប.ព.ស និង ច.ប.ត.រ ។

៦.២.៦ អ្នកបោះឆ្នោតជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបយ.ស ទាំងអស់ក្នុងតំណែង អាចស្នាក់នៅជុំគ្នានៅថ្ងៃមុនថ្ងៃបោះឆ្នោតក្នុងទីប្រជុំជនរាជធានី ខេត្តដែលការិយាល័យបោះឆ្នោតរបស់ពួកគាត់តាំងនៅ។ ការស្នាក់នៅនេះមិនចាត់ទុកថា ជាសកម្មភាពឃោសនាបោះឆ្នោតឡើយ។

**ប្រការ ៦.៣.-**

គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អាចលើកស្លាកសញ្ញាគណបក្ស ឬបិទផ្សាយឯកសារឃោសនាបោះឆ្នោតបម្រើឱ្យគោលដៅឃោសនាបោះឆ្នោតបាននៅតាមលំនៅឋានឯកជន ឬនៅទីកន្លែងសាធារណៈ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

៦.៣.១ ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

៦.៣.២ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៦៣.៣ ហាមគណបក្សនយោបាយលើក ឬបិទស្លាកគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនមិន

មានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទ ស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណរបស់គណបក្សណាមួយបាន។

៦.៣.៤ ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារឃោសនារបស់គណបក្សនយោបាយដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៦.៣.៥ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

**ប្រការ ៦.៤.-**

ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈជាឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៤.១ ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនជាសម្បត្តិរបស់រដ្ឋ ដែលមានស្លាកលេខ ឬដោះស្លាកលេខចេញ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនជាសម្បត្តិរបស់រដ្ឋដែលមានស្លាកលេខ ឬដោះស្លាកលេខចេញ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

៦.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ត្រូវបានកំណត់ដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬ/និងរដ្ឋនគរបាល ខេមរភូមិន្ទ ឬរាជរដ្ឋាភិបាល។

៦.៤.៣ ការដឹកជញ្ជូនមានលក្ខណៈប្រមូលផ្តុំ ឬរៀបចំទុកជាមុនត្រូវហាមឃាត់ លើកលែងតែករណីចាំបាច់មានការសម្រេចផ្សេងពីនេះ ដោយ គ.ជ.ប។

**ប្រការ ៦.៥.-**

ការស្លៀកពាក់ (សម្លៀកបំពាក់ មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា ឬសារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត។

**ប្រការ ៦.៦.-**

គណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតយ៉ាងច្រើន ២ (ពីរ) ដង នៅក្នុងមណ្ឌលភូមិភាគដែលគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

៦.៦.១ ក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវធ្វើឡើងក្នុងក្របខណ្ឌព្រំប្រទល់ភូមិភាគ ដែលសាមីគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះ។

៦.៦.២ ការហែក្បួនឃោសនាបោះឆ្នោត ត្រូវបានកំណត់ដោយទម្រង់ និងទំហំដូចខាងក្រោម៖

- មានការរៀបចំដំណើរជាក្បួន មានបិទបដា ពាក្យស្លោក សារនយោបាយនៅភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត និងមានការចាក់ផ្សាយដោយឧគ្ឃោសនស័ព្ទ។
- ចំនួនអ្នកចូលរួមមានចាប់ពី ១០ (ដប់) នាក់ឡើងទៅ ដោយប្រើប្រាស់យានជំនិះគ្រប់ប្រភេទក្នុងការឃោសនាបោះឆ្នោតមាន៖
    - រថយន្តចាប់ពី ១ (មួយ) គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ៥ (ប្រាំ) គ្រឿងឡើងទៅ ឬ

- ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ១០ (ដប់) គ្រឿងឡើងទៅ ។

៦.៦.៣ ក្នុងករណីគណបក្សនយោបាយមានបំណងហែក្បួនឃោសនាឆ្លងកាត់រាជធានី ខេត្តពីរ ឬច្រើនដែលមានព្រំប្រទល់ជាប់គ្នា សាមីគណបក្សនយោបាយនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ខប ពាក់ព័ន្ធយ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនា។ មណ្ឌលភូមិភាគពាក់ព័ន្ធដែលសាមីគណបក្សនយោបាយបានហែក្បួនឆ្លងកាត់នោះ ត្រូវចាត់ទុកថាបានហែមួយដងរួចហើយ។

៦.៦.៤ គធ.ខប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីសម្របសម្រួល ទីកន្លែង ផ្លូវ ពេលវេលា និងកម្មវិធីនៃការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ។

៦.៦.៥ ក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ត្រូវរក្សានូវសណ្តាប់ធ្នាប់ល្អតាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**ប្រការ ៦.៧.-**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ៖

៦.៧.១ ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជា ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។

៦.៧.២ ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោតស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧.៣ ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ។ ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការដូចខាងលើ ដែលកំពុងបំពេញភារកិច្ចត្រូវបានកំណត់ ដូចតទៅ៖

៦.៧.៣.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៦.៧.៣.២ ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៦.៧.៣.៣ ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧.៣.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧.៣.៥ ការធ្វើសកម្មភាពចែកចាយសម្ភារដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៦.៧.៣.៦ ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៦.៧.៣.៧ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

**ប្រការ ៦.៨.-**

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ

ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួន ហើយមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

## ប្រការ ៦.៩.-

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងនៅក្នុងការបោះឆ្នោត។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីដូចខាងក្រោម៖

៦.៩.១ ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តួចផ្តើម ឬការចូលរួមឃោសនារួមមាន៖

៦.៩.១.១ ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.១.២ ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.១.៤ ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ។

៦.៩.២ ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀង រួមមាន៖

៦.៩.២.១ ការស្ទង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បី

គាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៣ ផ្ដល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្ដល់មធ្យោបាយជាថវិកាសម្ភារ បរិក្ខារ ធនធានមនុស្ស រួមមាន៖

៦.៩.៣.១ ការផ្ដល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៣.២ ការផ្ដល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗ ជូនប្រជាពលរដ្ឋសម្រាប់ចូលរួមឃោសនាបោះឆ្នោត ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៣.៣ ការផ្ដល់ថវិកា សម្ភារ និងបរិក្ខារ សម្រាប់ក្បួនដង្ហែឃោសនាបោះឆ្នោត ការជួបជុំជាសាធារណៈ ការសម្ដែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនាបោះឆ្នោត ទោះដោយផ្ទាល់ក្ដី ឬប្រយោលក្ដី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៤ ហាមជនបរទេស ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការ

ឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

**ប្រការ ៦.១០..**

មុននឹងបើកការឃោសនាបោះឆ្នោត គធ.ខប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានរៀបរាប់ក្នុងប្រការ ៦.៧ ខាងលើ តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ នគរបាលជាតិថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការទាក់ទិនដល់ការឃោសនាបោះឆ្នោត។

**ប្រការ ៦.១១..**

គធ.ខប ត្រូវរៀបចំកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងតាមការចាំបាច់ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បី៖

៦.១១.១ ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត។

៦.១១.២ ជម្រាបជូនជាសង្ខេបពី ប.ន.ព.ស។

៦.១១.៣ ស្តាប់មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេងៗ។

៦.១១.៤ ពិភាក្សាលើបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត។

**ប្រការ ៦.១២.-**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ និងបេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុង ច.ប.ព.ស និងក្រមសីលធម៌ គោរពតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៦.១២.១ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ។

៦.១២.២ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ។

៦.១២.៣ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.១២.៤ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើ

រំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ។

៦.១២.៥ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថមាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់ឡើយ។

៦.១២.៦ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ។

៦.១២.៧ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត។

៦.១២.៨ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បី

ឱ្យគេគាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ។ ការគំរាមកំហែង និងបំបាក់ទឹកចិត្ត រួមមានៈ

៦.១២.៨.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។

៦.១២.៨.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម។

៦.១២.៨.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់។

៦.១២.៨.៤ ការរំលោភដោយពាក្យសម្ដីថា នឹងធ្វើទុក្ខទោសដល់រាងកាយ។

៦.១២.៨.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ។

៦.១២.៨.៦ ការលើកឡើងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលយោងទៅព្រឹត្តិការណ៍ពីអតីតកាលដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់។

៦.១២.៨.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលណាម្នាក់។

៦.១២.៨.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន។

៦.១២.៨.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន។

៦.១២.៨.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬការធ្វើឱ្យខូចប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត។

៦.១២.៨.១១ ការប្រមូល ឬការដកហូត ឬការបំផ្លាញឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោត។

៦.១២.៨.១២ ការដាក់កំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្តាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា។

**ប្រការ ៦.១៣.-**

គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងចំណុចទាំងឡាយក្រោមប្រការ ៦.១២ ខាងលើ នឹងត្រូវទទួលទោសតាមបញ្ញត្តិនៃ ច.ប.ព.ស និង ច.ប.ត.រ។

## សម្ភារអប់រំអ្នកបោះឆ្នោត

**ប្រការ ៦.១៤.-**

នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការបោះឆ្នោត។

៦.១៤.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចូលរួមការអប់រំផ្សព្វផ្សាយដើម្បីឱ្យការអប់រំសាធារណជនអំពីការបោះឆ្នោតកាន់តែមានប្រសិទ្ធភាពខ្ពស់។

៦.១៤.២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃ

ការអប់រំសាធារណជនអំពីការបោះឆ្នោត អាចទាក់ទងជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ។

៦.១៩.៣ សម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវតែអព្យាក្រឹត និងមិនលម្អៀង ។ សម្ភារនោះមិនត្រូវគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយ ហើយត្រូវគោរពទៅតាមច្បាប់បោះឆ្នោត និង ប.ន.ព.ស នេះ។

៦.១៩.៤ សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំដែលផលិតដោយ គ.ជ.ប និងសម្ភារអប់រំដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ។

៦.១៩.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេស និងតាមច្បាប់បោះឆ្នោត ហើយនិងតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រម និងណែនាំដល់អង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារអប់រំនេះ។

៦.១៥.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យផ្ទៀងផ្ទាត់ យល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ។

៦.១៥.៧ ទោះបីជាសម្ភារអប់រំត្រូវបានទទួល ឬមិនត្រូវបានទទួលការយល់ព្រមក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារអប់រំទាំងនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ។ ម្ចាស់សម្ភារអប់រំត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៦.១៥.៨ ក្នុងករណីដែលមានការស្នើសុំការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយ ដែលមានចែងក្រោមប្រការ ៦.១៦ មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ យល់ព្រមក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោងបន្ទាប់ពីទទួលបានសំណើសុំពីអង្គការមិនមែនរដ្ឋាភិបាលនានាសុំឱ្យជួយពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំនោះ។ ក្នុងករណីពិនិត្យឃើញថា សម្ភារ ឬខ្លឹមសារអប់រំមិនសមស្របតាមច្បាប់ បទបញ្ជា និងនីតិវិធី គណៈកម្មការសម្របសម្រួលត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវ និងប្រគល់ឱ្យគណៈកម្មការសម្របសម្រួលពិនិត្យឡើងវិញ ។ ក្នុងករណី

គណៈកម្មការសម្របសម្រួល ធ្វើការពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន។

៦.១៥.៩ សម្ភារអប់រំដែលអាចត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប មានដូចជា៖

៦.១៥.៩.១ ស្ប៉ុតវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ។

៦.១៥.៩.២ កាសែ្សតម៉ាញ៉េ ឬខ្សែអាត់សំឡេង ឬស៊ីឌី (CD) ឬអឹមភីស្រ៊ី (MP3) ឬយូអេសប៊ី (USB)។

៦.១៥.៩.៣ ខិត្តប័ណ្ណផ្សេងៗ និងបដា។

៦.១៥.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត។

៦.១៥.៩.៥ ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន។

៦.១៥.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក។

៦.១៥.១០ សម្ភារដែលបានពិនិត្យ ផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខ ១ (មួយ) ច្បាប់ សម្រាប់ជាឯកសារ។

៦.១៤.១១ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យ ផ្ទៀងផ្ទាត់យល់ព្រមដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវតាមបញ្ញត្តិនៃ ច.ប.ព.ស និង ច.ប.ត.រ។ ប្រសិនបើព័ត៌មានដែលមានក្នុងសម្ភារអប់រំដែលខ្លួនបានផលិតនោះ ត្រូវបានរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយពុំត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធី ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ព.ស ច.ប.ត.រ និង ប.ន.ព.ស គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារនោះទាំងស្រុងតែម្តង ។ សម្ភារដែលរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចចំណុច ៦.១៥.៥ ខាងក្រោម ។

៦.១៤.១២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សទាំងអស់ដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋាន មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតតែប៉ុណ្ណោះ ។

៦.១៤.១៣ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬសម្ភារអប់រំទាំងអស់ដែលមិនគោរពតាមចំណុច ៦.១៤.៣ ចំណុច ៦.១៤.១២ និងចំណុច ៦.១៥.៥ សាមីអង្គការត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គ.ជ.ប ជាចាំបាច់ ។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាម ច.ប.ព.ស និង ច.ប.ត.រ ។

## រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ

### ប្រការ ៦.១៥.-

យោងតាមប្រការ ៦.២ នៃ ប.ន.ព.ស នេះ គណបក្សនយោបាយបេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាផ្សព្វផ្សាយ បានដូចជា៖

៦.១៥.១ ខិត្តប័ណ្ណឃោសនាបោះឆ្នោត។

៦.១៥.២ ការឃោសនាតាមរលកអាកាស ឬតាមឧបករណ៍បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព។

៦.១៥.២.១ អត្ថបទឃោសនា។

៦.១៥.២.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ។

៦.១៥.២.៣ ការសូត្រកំណាព្យ។

៦.១៥.២.៤ ការប្រគំតន្ត្រីនៅនឹងកន្លែង។

៦.១៥.២.៥ សម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្តផ្ទាល់។

៦.១៥.២.៦ ការសម្ដែងសិល្បៈ។

៦.១៥.២.៧ ការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីផ្លាសាធារណៈ។

៦.១៥.២.៨ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្ដាញសង្គមផ្លូវការរបស់ខ្លួន។

៦.១៥.៣ ដោយយោងលើរូបភាព និងសម្ភារឃោសនាបោះឆ្នោតដូចបានបញ្ជាក់ខាងលើ មធ្យោបាយផ្សេងៗទៀតរួមមាន៖

៦.១៥.៣.១ រឿងល្ខោនខ្លីៗ និងការសម្ដែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្ត វីដេអូ។

៦.១៥.៣.២ ប៉េងប៉ោង ឬ/និងខ្លែង។

៦.១៥.៣.៣ សម្ភារបោះពុម្ព មានជាអាទិ៍ រូបភាពបិទផ្សាយ សម្លៀកបំពាក់ អាវយឺត មួក ស្លាកសញ្ញាពាក្យស្លោក ឬរូបភាពបិទតាមរថយន្ត ស្លាកសញ្ញា លោហៈខ្វាស់ បដា។

៦.១៥.៣.៤ ការស្រែកឃោសនាតាមទីសាធារណៈ។

៦.១៥.៤ គ្រប់សម្ភារ ឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជន ឬ/

និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសម្គាល់របស់សាមីគណបក្ស (ឈ្មោះ ឬ/និងអាសយដ្ឋាន)។

៦.១៥.៥ សម្ភារអប់រំ និងសម្ភារឃោសនាដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬតាមឧបករណ៍បំពងសំឡេង ឬការចាក់ផ្សាយ មិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាពណាមួយ ដូចខាងក្រោម៖

៦.១៥.៥.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសម្ងាត់នៃការបោះឆ្នោត។

៦.១៥.៥.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថ សម្តែងការមាក់ងាយ ឬអសីលធម៌ ឬការរើសអើងប្រកាន់ពូជសាសន៍។

៦.១៥.៥.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រោះភាពភ័យខ្លាច ធ្វើឱ្យភាន់ច្រឡំប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ និងខូចរបៀបរបបសង្គម។

៦.១៥.៥.៤ ប្រើប្រាស់រូបភាព ឬភាសាដែលមានព័ត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត។

៦.១៥.៥.៥ ប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។

៦.១៥.៦ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារអប់រំ និងសម្ភារឃោសនា ដែលត្រូវបានរកឃើញថារំលោភចំណុច ៦.១៥.៥ ខាងលើ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារខុសច្បាប់ទាំងនោះ។

៦.១៥.៧ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារអប់រំ និងសម្ភារឃោសនាដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើសម្ភារទាំងនោះរំលោភលើលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៦ នៃ ប.ន.ព.ស នេះ។

៦.១៥.៨ ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីយ៍ ព្រះវររាជមាតា និងរូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត។

៦.១៥.៩ ហាមលើកបដាឃោសនា ស្លាកសញ្ញាគណបក្សនយោបាយ និងរូបសញ្ញាណាមួយ ដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ កាត់ទទឹងផ្លូវសាធារណៈ។

## ប្រការ ៦.១៦.-

គ.ជ.ប ត្រូវបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ហៅកាត់ថា "គណៈកម្មការសម្របសម្រួល" តាមសេចក្ដីសម្រេចរបស់ គ.ជ.ប ដើម្បីពិនិត្យសម្ភារអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាល ឬ/និងសម្ភារឃោសនារបស់គណបក្សនយោបាយក្នុងករណីមានការតវ៉ា ឬមានបណ្ដឹង ព្រមទាំងរៀបចំគោលការណ៍កម្មវិធីស្មើភាព និងសមធម៌។

៦.១៦.១ តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្របសម្រួល ត្រូវបានកំណត់ដូចខាងក្រោម៖

៦.១៦.១.១ ត្រួតពិនិត្យ និងកែសម្រួលលើខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីមានការស្នើសុំពីសាមីអង្គការ។

៦.១៦.១.២ ត្រួតពិនិត្យសម្ភារអប់រំអ្នកបោះឆ្នោត និងសម្ភារឃោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានបណ្ដឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាងដទៃទៀត ដោយយោងតាម ច.ប.ព.ស និង ច.ប.ត.រ និងយោងតាមចំណុច ៦.១២.៨

ចំណុច ៦.១៥.៥ និងចំណុច ៦.១៥.៨ នៃ ប.ន.ព.ស នេះ។

៦.១៦.១.៣ សម្របសម្រួលកម្មវិធីស្មើភាព និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ។

៦.១៦.១.៤ សម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ក្នុងពេលឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីមានឱកាសទិញ ឬជួលម៉ោងផ្សាយ ផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ។

៦.១៦.១.៥ សម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរៀបចំកម្មវិធីស្មើភាព និងសមធម៌សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

៦.១៦.២ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានគោលការណ៍រៀបចំកម្មវិធីស្មើភាព និងសមធម៌ ជូនគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជាផ្លូវការ មានឱកាសផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយនីមួយៗដល់អ្នកបោះឆ្នោត តាមវិទ្យុ

និងទូរទស្សន៍របស់រដ្ឋ ផ្អែកតាមគោលការណ៍របស់ គ.ជ.ប និងតាមលំដាប់មុនក្រោយ។

៦.១៦.២.១ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដើម្បីពិភាក្សាកំណត់អំពីការរៀបចំកម្មវិធីស្មើភាព និងសមធម៌ ហើយត្រូវមានបទបញ្ជាមួយសម្រាប់ចតកម្មវិធី ដែលអនុម័តដោយ គ.ជ.ប។

៦.១៦.២.២ គណៈកម្មការសម្របសម្រួលត្រូវអនុវត្តតាមគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព និងសមធម៌របស់ គ.ជ.ប ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ។

៦.១៦.៣ កម្មវិធីស្មើភាព និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម។

៦.១៦.៣.១ កម្មវិធីចាក់ផ្សាយកិច្ចពិភាក្សាតាមប្រធានបទរវាងបេក្ខជនឈរឈ្មោះបោះឆ្នោត ឬតំណាងគណបក្សនយោបាយអំពីកម្មវិធីនយោបាយរបស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។

៦.១៦.៣.២ កម្មវិធីចាក់ផ្សាយស្ប៉ុតរបស់គណបក្សនយោបាយតាមវិទ្យុ និងទូរទស្សន៍រដ្ឋ។

៦.១៦.៣.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនាអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតលើព្រឹត្តិបត្រគោលនយោបាយគណបក្សដែលបានបោះពុម្ពផ្សាយដោយ គ.ជ.ប។

៦.១៦.៤ គណៈកម្មការសម្របសម្រួលត្រូវជួបពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និងឯកជន និងភាគីពាក់ព័ន្ធ ដើម្បីពន្យល់ណែនាំអំពីបទបញ្ញា និងនីតិវិធី ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំអំពីការឃោសនាបោះឆ្នោតរបស់ គ.ជ.ប។

**ប្រការ ៦.១៧.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការស្នើសុំ។ គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងជួលរោងមហោស្រព ឬមណ្ឌលកីឡា ឧទ្យានសាធារណៈ ឬទីសាធារណៈ ឬសាលសាធារណៈត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ហើយត្រូវធ្វើសេចក្តីចម្លងនៃពាក្យសុំ

នេះ ១ (មួយ) ច្បាប់ ដល់ គជ.ឧប។ អ្នកគ្រប់គ្រងត្រូវឆ្លើយតបទៅនឹងពាក្យសុំ មិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ក្រោយពីបានទទួលពាក្យសុំ។

៦.១៧.១ គជ.ឧប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីកំណត់ទីសាធារណៈសម្រាប់ការឃោសនាបោះឆ្នោត ហើយត្រូវផ្សព្វផ្សាយជាសាធារណៈនៅក្នុងរាជធានី ខេត្ត យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត។

៦.១៧.២ បន្ទាប់ពីបានទទួលនូវសេចក្តីជូនដំណឹងដូចមានចែងក្នុងចំណុច ៦.១៧.១ គជ.ឧប ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីសម្របសម្រួល អំពីការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ឱ្យគណបក្សនយោបាយ ឬបេក្ខជនធ្វើការឃោសនាបោះឆ្នោត។

៦.១៧.៣ គជ.ឧប ត្រូវមានសៀវភៅសម្រាប់ចុះលិខិតចម្លងនៃពាក្យសុំធ្វើការឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដែលបានចម្លងជូន ដើម្បីឱ្យបានដឹងថា គណបក្សនយោបាយណាបានសុំធ្វើការឃោសនាមុន និងគណបក្សនយោបាយណាបានសុំធ្វើការឃោសនាបន្តបន្ទាប់។

៦.១៧.៤ គជ.ឧប ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ ស្តីពីកាលកំណត់តាមលំដាប់លំដោយនៃការសុំប្រើប្រាស់ទីធ្លាសាធារណៈ និងទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅ លគជ.ឧប ១ (មួយ) ច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការឃោសនា ១ (មួយ) ច្បាប់។

៦.១៧.៥ គធ.ខប ជាអ្នកសម្របសម្រួល និងរៀបចំតាមលំដាប់នៃការជូនដំណឹងស្តីពីការធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ដោយណែនាំឱ្យគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត និងចាត់វិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាបោះឆ្នោតទាំងឡាយណាដែលផ្ទុយនឹង ច.ប.ព.ស ច.ប.គ.រ និង ប.ន.ព.ស ។

## ប្រការ ៦.១៨.-

គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ត្រូវរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយឱ្យបានល្អ និងត្រឹមត្រូវតាមពេលវេលា ទីកន្លែងកំណត់ តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ។

## ប្រការ ៦.១៩.-

គណបក្សនយោបាយ ឬបេក្ខជនអាចធ្វើសកម្មភាពឃោសនានៅតាមកន្លែងឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ខប យ៉ាងតិច៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ។ អ្នកគ្រប់គ្រងទីកន្លែងត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់គ្រប់បេក្ខជន ឬគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតដែលមានបំណងជួលប្រើប្រាស់សម្រាប់បម្រើការឃោសនា ដោយផ្អែកលើតម្លៃស្មើៗគ្នា និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការសុំជួល។

**ប្រការ ៦.២០.-**

គណបក្សនយោបាយ ឬ/និងបេក្ខជន ឬ/និងអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬ/និងអ្នកគាំទ្រផ្សេងទៀតឡើយ ។ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខាន រាំងស្ទះនោះរួមមាន ៖

៦.២០.១ ការនិយាយដៀមដាម ប្រមាថមើលងាយ ។

៦.២០.២ ការធ្វើទុក្ខទោសដល់រាងកាយ ។

៦.២០.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់ ។

៦.២០.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ។

៦.២០.៥ ការរារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមកាលកំណត់។

៦.២០.៦ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ទច់បង្អាក់មិនឱ្យក្បួនដង្ហែឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀត។

៦.២០.៧ ការហាមឃាត់ ឬរារាំងប្រជាពលរដ្ឋមិនឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ។

៦.២០.៨ ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន។

៦.២០.៩ ការប្រើឧបករណ៍បំពងសំឡេងដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនា ឬការជួបប្រជុំ។

៦.២០.១០ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្សនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ។

**ប្រការ ៦.២១.-**

បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការទទួលបានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៦.២១.១ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការឃោសនាបោះឆ្នោត។

៦.២១.២ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវ ដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការ

ទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

៦.២១.៣ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិដែលមានភារកិច្ចការពារ មិនត្រូវឈរក្បែរ ឬដើរកៀកពេកទៅនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ ។

៦.២១.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គជ.ខប ត្រូវតាមដានជារៀងរាល់ថ្ងៃអំពីកម្រិតសន្តិសុខ និងសុវត្ថិភាពក្នុងរាជធានី ខេត្ត និងត្រូវជូនព័ត៌មានទៅ គ.ជ.ប ជារៀងរាល់ថ្ងៃ ។

**ប្រការ ៦.២២.-**

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនី ដើម្បីកត់ត្រាចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការឃោសនាបោះឆ្នោត ។

៦.២២.១ វិភាគទានទាំងអស់ដែលគណបក្សនយោបាយទទួលបានត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនាត្រូវតែចេញពីគណនីតែមួយនេះ។

៦.២២.២ គ.ជ.ប អាចត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត តាមការចាំបាច់។

## កិច្ចសហការ និងភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និង គ.ជ.ប

### ប្រការ ៦.២៣._

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតជូនសាធារណជន និងតាមដានការផ្សព្វផ្សាយ ត្រួតពិនិត្យ និងចាត់វិធានការ ក្នុងករណីមិនគោរពតាមច្បាប់បោះឆ្នោត និង ប.ន.ព.ស ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ។

### ប្រការ ៦.២៤._

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ឯកជន ដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ត្រូវអនុវត្តតាមក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។

### ប្រការ ៦.២៥._

គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងរដ្ឋ ទាំងឯកជនត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី

របស់ គ.ជ.ប ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

**ប្រការ ៦.២៦.-**

រាល់បណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី ៩ នៃ ប.ន.ព.ស នេះ។

# បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា

# សម្រង់ជំពូកទី ៧
# ប្រការ ៧.៥
# អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ

**ប្រការ ៧.៥.-**

សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ ដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់ នៅ គ.ជ.ប ។

៧.៥.១ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ត្រូវអនុវត្តការងារទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកសារព័ត៌មានជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានឯករាជ ដែលចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

៧.៥.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មាន ដល់សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ តាមការស្នើសុំដោយឥតគិតថ្លៃ ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័រ គ.ជ.ប (www.necelect.org.kh) ។

៧.៥.២.១ រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ គឺចាប់ផ្ដើមពីថ្ងៃជូនដំណឹងរហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៧.៥.២.២ រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានអន្តរជាតិ គឺចាប់ផ្ដើមពីថ្ងៃជូនដំណឹងរហូតដល់ ៣ (បី) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៧.៥.៣ ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម ៖

៧.៥.៣.១ សម្រាប់អ្នកសារព័ត៌មានជាតិ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតស្នើសុំធ្វើបណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃបណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប ។

៧.៥.៣.២ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតស្នើសុំធ្វើបណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃបណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន (សម្រាប់ជនបរទេស) ។

៧.៥.៣.៣ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិ ដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យដោយផ្ទាល់នៅ គ.ជ.ប ឬតាមរយៈអ៊ីមែល necinfo@forum.org.kh ត្រូវភ្ជាប់ជាមួយនូវ ៖

- ច្បាប់ចម្លងនៃលិខិតឆ្លងដែន
- បណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មាន របស់សាមីអង្គភាព

- ប្រវត្តិរូបសង្ខេប ។

៧.៥.៣.៤ សម្រាប់អ្នកសារព័ត៌មានឯករាជ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងនៃបណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមអ្នកសារព័ត៌មាន

- ប្រវត្តិរូបសង្ខេប

- អត្ថបទចុងក្រោយ ដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់ក្នុងអំឡុងឆ្នាំចុងក្រោយចំនួន ៣ (បី) អត្ថបទ។

៧.៥.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ សម្រាប់អ្នកសារព័ត៌មានជាតិ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មាន អាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតបដិសេធ។

៧.៥.៥ គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មាន

អន្តរជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀតក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ។

៧.៥.៦ គ.ជ.ប ត្រូវបោះពុម្ពបណ្ណសម្គាល់អ្នកសារព័ត៌មានជាតិ និងបណ្ណសម្គាល់អ្នកសារព័ត៌មានអន្តរជាតិ ដើម្បីផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកសារព័ត៌មាន ដែលត្រូវបានអនុញ្ញាតឱ្យយកព័ត៌មានដោយ គ.ជ.ប ដើម្បីពាក់ក្នុងពេលបំពេញការងារ។

៧.៥.៧ អ្នកសារព័ត៌មាន ត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ច.ប.ព.ស ច.ប.ត.រ ប.ន.ព.ស ក្រមសីលធម៌របស់ គ.ជ.ប និងវិជ្ជាជីវៈអ្នកសារព័ត៌មាន។

៧.៥.៨ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលបានទទួលការអនុញ្ញាតដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូល ដោយត្រូវគោរព ច.ប.ព.ស ច.ប.ត.រ ប.ន.ព.ស និងគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។

៧.៥.៩ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិមានសិទ្ធិថត និងយកព័ត៌មាន។

៧.៥.១០ ការយកព័ត៌មានដោយរូបភាពក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន គ.ក.ប/គ.ក.រ ជាមុន។

៧.៥.១១ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិមិនត្រូវ៖

- ជ្រៀតជ្រែក ឬរំខានដល់ការងារបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ធ្វើសម្ភាសន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧.៥.១២ អ្នកសារព័ត៌មានមិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើសមាជិក គ.ក.ប/គ.ក.រ ឬអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ។

# ឧបសម្ព័ន្ធ ក

## សម្រង់ជំពូកទី ៥ ស្តីពីការឃោសនាបោះឆ្នោត នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

**មាត្រា ១៦.-**

ការឃោសនាបោះឆ្នោត មានទិសដៅឱ្យបេក្ខជន និងគណបក្សនយោបាយដែលបានចុះបញ្ជី ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត ។

**មាត្រា ១៧.-**

ការឃោសនាបោះឆ្នោត ត្រូវធ្វើនៅតាមមណ្ឌលភូមិភាគនីមួយៗ ។

យុទ្ធនាការឃោសនាបោះឆ្នោត មានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត ។

**មាត្រា ១៨.-**

មាត្រា៦៨ ៦៩ ៧០ ៧១ កថាខ័ណ្ឌទី២ នៃមាត្រា៧២ មាត្រា៧៣ ៧៤ ៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ និងមាត្រា៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ដោយឡែក ចំពោះការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅក្នុងមណ្ឌលភូមិភាគនីមួយៗ ត្រូវកំណត់យ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

# ឧបសម្ព័ន្ធ ២

## សម្រង់មាត្រាមួយចំនួនក្នុងជំពូកទី ១០ ស្តីពីទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

**មាត្រា ១៤២.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត ៖

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោត ប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សា ទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត ។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១៤៣.-**

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា ១៤២ ខាងលើនេះ ។

**មាត្រា ១៤៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៨៧ នៃច្បាប់នេះ ។

**មាត្រា ១៤៩.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍ ។

**មាត្រា ១៥២.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុម

ជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

**មាត្រា ១៥៣.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥២ ខាងលើនេះ ។

**មាត្រា ១៥៤.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៨ ឬកថាខណ្ឌទី ២ នៃមាត្រា ៧៩ នៃច្បាប់នេះ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ១៥៥.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ១ នៃមាត្រា ៧២ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

## មាត្រា ១៥៦.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចបានចែងក្នុងមាត្រា ១៥៥ ខាងលើនេះ ។

## មាត្រា ១៥៧.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ២ នៃមាត្រា ៧២ នៃច្បាប់នេះ ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១៥៨.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៥៩.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៣៧ នៃច្បាប់នេះ ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។

### មាត្រា ១៦២.-

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ ។

អង្គការឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ ។

### មាត្រា ១៦៣.-

បែបបទ និងនីតិវិធី ដើម្បីចេញសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ១៦៤.-

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ ពីសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងនៅក្នុងជំពូកនេះ អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងអំឡុងពេល ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីកាលបរិច្ឆេទទទួលបានសេចក្ដីសម្រេចនេះ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ាខាងលើក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានពាក្យបណ្ដឹងតវ៉ា។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

**មាត្រា ១៦៥.-**

ដំណើរការនីតិវិធី ដើម្បីចេញសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬក្រុមប្រឹក្សាធម្មនុញ្ញ មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងនៅក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា ១៦៦.-**

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី ១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី ៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្ដីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ ។

# ឧបសម្ព័ន្ធ គ

## គោលការណ៍

## សម្រាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត

- អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។
- អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចេញគោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្ស ដើម្បីផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ត្រូវអនុវត្តដូចខាងក្រោម ៖

## ១. កិច្ចសហការជាមួយ គ.ជ.ប

### ១.១ ការពិគ្រោះយោបល់

អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអាចពិគ្រោះយោបល់ជាមួយគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព គ.ជ.ប មុននឹងចាប់ផ្ដើមធ្វើកម្មវិធីនេះ លើបញ្ហាមួយចំនួនដូចជា ៖

- លក្ខណៈបច្ចេកទេសដែលត្រូវរៀបចំធ្វើ
- ប្រធានបទ ឬសំណួរដែលត្រូវដាក់ជូនគណបក្សនយោបាយ
- ការសម្របសម្រួលទីតាំងប្រជុំ និងសន្តិសុខ សុវត្ថិភាព ។

### ១.២ ការទទួលខុសត្រូវ

សាមីអង្គការ ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលរៀបចំកម្មវិធីត្រូវទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយគោលនយោបាយនេះ និងទទួលបន្ទុករាល់ការចំណាយទាំងអស់ ។

## ២. កិច្ចដំណើរការកម្មវិធី

កម្មវិធីសំណួរចម្លើយ ឬពិភាក្សា ត្រូវធ្វើឡើងជាមួយគណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។ កម្មវិធីនេះអាចធ្វើនៅទីសាធារណៈ ឬឯកជន ថ្នាក់ភូមិភាគ ឬនៅថ្នាក់ជាតិ និងតាមស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ផ្ទាល់ ។ ដើម្បីឱ្យដំណើរការកម្មវិធីសំណួរចម្លើយ ឬពិភាក្សានេះប្រព្រឹត្តទៅមានភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយដែលចូលរួមការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ អង្គការមិន

មែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

## ២.១ ការត្រៀមរៀបចំមុនកម្មវិធីចាប់ផ្ដើមដំណើរការ

- ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរ អញ្ជើញតំណាងគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ជាផ្លូវការ ដើម្បីឱ្យចាត់តាំងតំណាងរបស់ខ្លួនចូលរួមក្នុងកម្មវិធីសំណួរចម្លើយ ឬពិភាក្សា។

- យោងតាមកម្រិតនៃការរៀបចំនៅថ្នាក់ភូមិភាគ ឬនៅថ្នាក់ជាតិ ការធ្វើលិខិតអញ្ជើញនេះ ត្រូវអញ្ជើញគ្រប់គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមភូមិភាគ ឬគណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ នេះ។

- ក្នុងករណីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីនៅតាមភូមិភាគ ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមភូមិភាគ ឬនៅទូទាំងប្រទេស បានចូលរួម ។

- ត្រូវផ្ដល់ប្រធានបទ និងសំណួរ ដែលត្រូវចោទសួរក្នុងកម្មវិធីសំណួរចម្លើយ ឬពិភាក្សា ជូនគណបក្សនយោបាយយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃចាប់ផ្ដើមកម្មវិធី ។

- ក្នុងករណីដែលគណបក្សនយោបាយបានទទួលលិខិតអញ្ជើញនោះហើយ តែពុំបានចាត់តំណាងរបស់ខ្លួនឱ្យមកចូលរួមក្នុងកម្មវិធីតាមកាលបរិច្ឆេទកំណត់ មានន័យថា គណបក្សនយោបាយនោះ បោះបង់ចោលពេលវេលារបស់ខ្លួន ហើយកម្មវិធីនេះនឹងត្រូវដំណើរការធម្មតាទៅតាមកាលបរិច្ឆេទកំណត់ ។

## ២.២ ទីកន្លែងដំណើរការកម្មវិធី និងសមាសភាពចូលរួម

- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចធ្វើនៅទីសាធារណៈ ឬកន្លែងឯកជននៅតាមរាជធានី ខេត្ត នៃភូមិភាគ ។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចធ្វើនៅនឹងស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ផ្ទាល់តែម្តង ។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចអញ្ជើញប្រជាពលរដ្ឋចូលរួមស្តាប់ និងចោទសំណួរបាន ប្រសិនបើអ្នកគ្រប់គ្រងកម្មវិធីចង់ឱ្យមាន ។

## ២.៣ អ្នកសម្របសម្រួលកម្មវិធី

អ្នកសម្របសម្រួលកម្មវិធីសំណួរចម្លើយ ឬពិភាក្សា ត្រូវប្រកាន់ជំហរអព្យាក្រឹត យុត្តិធម៌ និងមានសមត្ថភាពក្នុងការគ្រប់គ្រងកិច្ចដំណើរការកម្មវិធីឱ្យបានល្អ និងសុវត្ថិភាព។

## ២.៤ ការផ្សព្វផ្សាយ កម្មវិធីសំណួរចម្លើយ ឬពិភាក្សា តាមវិទ្យុ និងទូរទស្សន៍

កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្ស ដែលត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ត្រូវបានអនុវត្តដូចខាងក្រោម ៖

- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា ដែលធ្វើនៅតាមភូមិភាគណា អាចធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដែលមានស្ថានីយនៅក្នុងរាជធានី ខេត្ត នៃភូមិភាគនោះ ។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍នៅថ្នាក់ជាតិបាន លុះត្រាតែមានការចូលរួមគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជាផ្លូវការទាំងអស់ក្នុងភូមិភាគណាមួយ ឬទូទាំងប្រទេស ។

## ៣. គោលការណ៍អនុវត្ត

- អ្នកគ្រប់គ្រងកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយគណបក្ស ត្រូវតែអព្យាក្រឹត និងមិនលម្អៀង ។
- ការផ្សព្វផ្សាយកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយគណបក្ស ពុំតម្រូវឱ្យមានលិខិតយល់ព្រមពី គ.ជ.ប ឡើយ ។ ប៉ុន្តែអ្នកគ្រប់គ្រងកម្មវិធីនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតក្នុងករណីមានកំហុសលើដំណើរការនៃការផ្សាយកម្មវិធី ។
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវគោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ និងគោលការណ៍នេះ ៕

# ឧបសម្ព័ន្ធ ឃ

## គោលការណ៍សម្រាប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយ ឱ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយអំពីកម្មវិធីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងអំឡុងពេលឃោសនាបោះឆ្នោត

- អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។
- អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចេញគោលការណ៍សម្រាប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្ស ក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ដល់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ដែលមានបំណងរៀបចំកម្មវិធីផ្សព្វផ្សាយគោលនយោបាយ និង

កម្មវិធីនយោបាយរបស់គណបក្ស ដោយលក់ ឬជួលម៉ោងផ្សាយទៅឱ្យគណបក្សនយោបាយ ត្រូវអនុវត្តដូចខាងក្រោម ៖

## ១. សេចក្តីប្រកាសជាសាធារណៈ

១.១ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ត្រូវប្រកាសជាសាធារណៈអំពីចំនួនម៉ោងដែលខ្លួនមានសម្រាប់លក់ ឬជួលក្នុងរយៈពេល ១ (មួយ) ថ្ងៃ និងចំនួនម៉ោងដែលមានសម្រាប់លក់ ឬជួលក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ នៃដំណាក់កាលឃោសនាបោះឆ្នោត ។

១.២ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈអំពីតម្លៃដែលលក់ ឬជួលនោះ ។

១.៣ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ត្រូវជូនដំណឹងអំពីការលក់ ឬជួលម៉ោងផ្សាយនេះ ទៅគ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ហើយសេចក្តីជូនដំណឹងនេះត្រូវចម្លងជូនមក គ.ជ.ប ចំនួន ១ (មួយ) ច្បាប់ ។

១.៤ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ត្រូវផ្តល់ព័ត៌មានមក គ.ជ.ប អំពីឈ្មោះគណបក្សនយោបាយដែលបានទិញ ឬជួលម៉ោងផ្សាយ ។

## ២. វិធីលក់ ឬជួលម៉ោងឱ្យគណបក្សនយោបាយ

២.១ ការលក់ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយរបស់គណបក្សនយោបាយ ត្រូវផ្អែកទៅតាមគោលការណ៍ស្មើភាព តម្លៃស្មើៗគ្នា និងតាមលំដាប់មុនក្រោយ ។

២.២ ម្ចាស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ត្រូវយកចំនួនម៉ោងសរុបដែលលក់ ឬជួល ចែកជាមួយនឹងចំនួនគណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ រួចលក់តែចំណែកម៉ោងដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបាន ទៅឱ្យគណបក្សនយោបាយនីមួយៗ ។

២.៣ ក្នុងករណីមានគណបក្សនយោបាយតិច ឬគណបក្សនយោបាយតែមួយទិញ ឬជួលម៉ោងផ្សាយ ម្ចាស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍អាចលក់ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយដែលមានលទ្ធភាពទិញ ឬជួលនោះ នូវរយៈពេលយ៉ាងច្រើន ២ (ពីរ) ដងនៃរយៈពេលផ្សព្វផ្សាយតាមគោលការណ៍ស្មើភាព ដូចមានចែងក្នុងចំណុច ២.២ ខាងលើ ។

២.៤ ការលក់ ឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយ មិនអនុញ្ញាតឱ្យម្ចាស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ លក់ ឬជួលម៉ោងផ្តាច់មុខឱ្យគណបក្សនយោបាយណាមួយឡើយ ។

## ៣- សិទ្ធិ និងការទទួលខុសត្រូវ

៣.១ ម្ចាស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ពុំត្រូវទទួលខុសត្រូវចំពោះខ្លឹមសារនៃការផ្សព្វផ្សាយគោលនយោបាយ របស់គណបក្សនយោបាយឡើយ ។

៣.២ គណបក្សនយោបាយ ត្រូវទទួលខុសត្រូវចំពោះខ្លឹមសារនៃការឃោសនារបស់ខ្លួន ។

៣.៣ ម្ចាស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ត្រូវគោរពតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤

ឆ្នាំ២០១៨ គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និង គោលការណ៍សម្រាប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ក្នុងការលក់ ឬ ជួលម៉ោងផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ដើម្បីផ្សព្វផ្សាយ អំពីគោលនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

៣.៤ ក្នុងករណី គ.ជ.ប រកឃើញថា ខ្លឹមសារនៃការឃោសនារំលោភ លើបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ គ.ជ.ប មានសិទ្ធិស្នើឱ្យ គណបក្សនយោបាយធ្វើការកែតម្រូវ ហើយប្រសិនបើនៅតែមិន ព្រមកែតម្រូវ គ.ជ.ប មានសិទ្ធិដកហូត ឬបញ្ឈប់លែងឱ្យស្ថានីយ៍ វិទ្យុ និងទូរទស្សន៍នោះធ្វើការផ្សព្វផ្សាយនូវខ្លឹមសារឃោសនាទាំង ស្រុង និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន ។

# ឧបសម្ព័ន្ធ ខ

# គោលការណ៍ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃកម្មវិធីផ្សាយ គោលនយោបាយរបស់គណបក្សនយោបាយ

- អនុលោមតាមច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- អនុលោមតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។
- អនុលោមតាមច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- អនុលោមតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

## ១. គោលបំណង

កម្មវិធីផ្សាយគោលនយោបាយរបស់គណបក្ស ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមភូមិភាគ ហើយដែលបានទទួលស្គាល់ជាផ្លូវការដោយ គ.ជ.ប មានឱកាសធ្វើការផ្សព្វផ្សាយ អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត សម្រាប់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ។

## ២. ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយ

ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ សម្រាប់ចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ដែលរៀបចំឡើងដោយ គ.ជ.ប មានដូចខាងក្រោម ៖

២.១ កម្មវិធីឆ្លើយសំណួរទៅតាមប្រធានបទដែលកំណត់ដោយ គ.ជ.ប ។

២.២ កម្មវិធីចាក់ផ្សាយស្ប៉ត (Spot) ដែលផលិតដោយសាមីគណបក្សនយោបាយតាមវិទ្យុ និងទូរទស្សន៍ ។

២.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឬថ្នាក់ដឹកនាំគណបក្ស នៅលើព្រឹត្តិបត្រគោលនយោបាយគណបក្ស ដែលបោះពុម្ពផ្សាយដោយ គ.ជ.ប ។

ការរៀបចំកម្មវិធីទាំង ៣ (បី) ខាងលើ ត្រូវស្ថិតក្រោមការរៀបចំ និងចាត់ចែងដោយគណៈកម្មការសម្របសម្រួល ដែលសម្រេចដោយ គ.ជ.ប ។

## ៣. ការអនុវត្តគោលការណ៍

ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ត្រូវអនុវត្តតាមគោលការណ៍ស្មើភាព ដោយគណបក្សនយោបាយនីមួយៗ ទទួលបាន

ម៉ោងផ្សាយតាមវិទ្យុជាតិ និងទូរទស្សន៍ជាតិកម្ពុជា ក្នុង ១ (មួយ) ថ្ងៃ រយៈពេល ១៥នាទី ហើយរយៈពេលនេះនឹងត្រូវចាក់ផ្សាយឡើងវិញក្នុងថ្ងៃដដែល ។

## ៤. ការទទួលខុសត្រូវរបស់គណបក្សនយោបាយ

គណបក្សនយោបាយ ត្រូវគោរពតាមការរៀបចំ និងចាត់ចែងដោយគណៈកម្មការសម្របសម្រួល ដែលរៀបចំការចាប់ឆ្នោតយកលំដាប់លេខរៀងមុនក្រោយ សម្រាប់ការថត ទីកន្លែងអង្គុយ ម៉ោងផ្សាយ និងគោរពបទបញ្ជាសម្រាប់ថតកម្មវិធី ។

គណបក្សនយោបាយដែលចូលរួមក្នុងកម្មវិធីផ្សាយគោលនយោបាយ ត្រូវតែគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ និងគោរពតាមគោលការណ៍នេះ ។

## ៥. ការទទួលខុសត្រូវខ្លឹមសារផ្សព្វផ្សាយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ជាអ្នកទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយ អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ដែលរៀបចំឡើងដោយ គ.ជ.ប ហើយត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ៕

# ឧបសម្ព័ន្ធ ច

## គោលការណ៍
## សម្រាប់បោះពុម្ព និងផ្សព្វផ្សាយអត្ថបទឃោសនា
## របស់គណបក្សនយោបាយក្នុងព្រឹត្តិបត្រគោលនយោបាយគណបក្ស

- អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។
- អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នឹងរៀបចំបោះពុម្ពព្រឹត្តិបត្រគោលនយោបាយគណបក្ស ចំនួន ២ (ពីរ) លេខ ក្នុងពេលឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

ដើម្បីឱ្យការបោះពុម្ពព្រឹត្តិបត្រនេះប្រព្រឹត្តទៅតាមគោលការណ៍ស្មើភាពគណបក្សនយោបាយដែលបានទទួលការយល់ព្រមជាផ្លូវការដោយ គ.ជ.ប នូវការចុះបញ្ជីបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិផ្តល់អត្ថបទស្តីពីគោលនយោបាយគណបក្សរបស់គណបក្សខ្លួនមក គ.ជ.ប ដើម្បីធ្វើការបោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈដោយឥតគិតថ្លៃ ។

គ.ជ.ប សម្រេចនូវគោលការណ៍ស្តីពីការបោះពុម្ពផ្សាយដូចខាងក្រោម ៖

## ១. លក្ខខណ្ឌនៃការបោះពុម្ព

១.១ អត្ថបទគោលនយោបាយគណបក្សត្រូវមានទំហំ A4 (21cm x 27cm)

Page Setup:
- Top = 2 cm
- Bottom = 2 cm
- Left = 2.5 cm
- Right = 1.5 cm

១.២ គណបក្សនយោបាយនីមួយៗ ត្រូវផ្តល់នូវអត្ថបទគោលនយោបាយរបស់ខ្លួន ចំនួន ២ (ពីរ) ទំព័រ A4 ក្នុង ១ (មួយ) លេខ ។

១.៣ គណបក្សនយោបាយត្រូវរចនាអត្ថបទឃោសនាឱ្យរួចរាល់មុននឹងផ្តល់មកឱ្យ គ.ជ.ប ។

១.៤ គណបក្សនយោបាយអាចផ្តល់នូវខ្លឹមសារឃោសនារបស់ខ្លួនជាអត្ថបទក៏បាន ឬជារូបភាព ស ខ្មៅ ស្តីពីសកម្មភាពរបស់គណបក្សខ្លួនក៏បាន ។

១.៥ គណបក្សនយោបាយអាចផ្តល់ខ្លឹមសារនៃការឃោសនានេះជាឯកសារក្រដាស (Hard Copy) ឬជាឯកសារក្នុងកុំព្យូទ័រ (Soft Copy) ។

១.៦ គណបក្សនយោបាយ ត្រូវផ្តល់អត្ថបទនៃការឃោសនាមកឱ្យ គ.ជ.ប បន្ទាប់ពី គ.ជ.ប ទទួលយល់ព្រមការចុះបញ្ជីគណបក្ស

នយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ រហូតដល់ ១៤ (ដប់បួន) ថ្ងៃ យ៉ាងតិច មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ។

១.៧ លេខរៀងទំព័រចុះផ្សាយក្នុងព្រឹត្តិបត្រ ត្រូវធ្វើការចាប់ឆ្នោតដោយតំណាងគណបក្សនយោបាយ ។

## ២. ការបែងចែក និងការផ្សព្វផ្សាយ

២.១ គណបក្សនយោបាយត្រូវចាត់តំណាងរបស់ខ្លួនមកទទួលព្រឹត្តិបត្រគោលនយោបាយគណបក្ស នៅ គ.ជ.ប ។

២.២ គ.ជ.ប ធ្វើការបែងចែក និងផ្សព្វផ្សាយដល់ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងអង្គការសង្កេតការណ៍បោះឆ្នោត ស្ថានទូត អ្នកសារព័ត៌មាន និងនៅតាមតូបលក់កាសែតសាធារណៈ ដោយឥតគិតថ្លៃ ។

## ៣. គោលការណ៍ច្បាប់

៣.១ ខ្លឹមសារអត្ថបទឃោសនារបស់គណបក្សនយោបាយ ត្រូវគោរពគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

៣.២ ក្នុងករណី គ.ជ.ប ពិនិត្យឃើញខ្លឹមសារនៃអត្ថបទឃោសនាប្រាសចាកពីគោលការណ៍ច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើស

តាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ គ.ជ.ប មានសិទ្ធិស្នើសុំឱ្យធ្វើការកែតម្រូវមុននឹងបោះពុម្ពផ្សាយ ។

៣.៣ ក្នុងករណីគណបក្សនយោបាយមិនអនុវត្តតាមការស្នើសុំឱ្យកែតម្រូវ គ.ជ.ប មិនចុះផ្សាយនូវអត្ថបទឃោសនានោះឡើយ ។

៣.៤ គ.ជ.ប មិនទទួលខុសត្រូវចំពោះគណបក្សនយោបាយដែលមិនគោរពតាមចំណុច ១.៦ ខាងលើ៕

**ឧបសម្ព័ន្ធ ឆ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

## ប្រតិទិននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ (វិសោធនកម្ម)

| ល.រ | ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត | ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ |
| ២ | ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ | ថ្ងៃទី២៨ ខែវិច្ឆិកា - ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ |
| ៣ | ការបំពេញបន្ថែមលើពាក្យសុំរបស់គណបក្សនយោបាយ និងការសម្រេចរបស់ គ.ជ.ប | ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ៤ | ការប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ រយៈពេល ៥ថ្ងៃ | ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ៥ | ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ រយៈពេល ១០ថ្ងៃ | ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ) |
| ៦ | ការបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ | ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ៧ | ការចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ និងនៅរដ្ឋសភា | ថ្ងៃទី១៩ ខែតុលា - ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ |
| ៨ | ការកែតម្រូវបញ្ជីឈ្មោះ និងការសម្រេចលើបញ្ជីបោះឆ្នោតដំបូងដោយ គ.ជ.ប | ថ្ងៃទី៩ ខែវិច្ឆិកា - ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ |
| ៩ | ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង | ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ |
| ១០ | ការប្តឹងតវ៉ា ឬជំទាស់ និងការដោះស្រាយពាក្យបណ្តឹងលើបញ្ជីបោះឆ្នោតដំបូងនៅ គធ.ឧប | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧-ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៨ |
| ១១ | ការប្តឹងតវ៉ា ឬជំទាស់ និងការដោះស្រាយបណ្តឹងលើបញ្ជីបោះឆ្នោតដំបូងនៅ គ.ជ.ប | ថ្ងៃទី១៥ - ២៤ ខែមករា ឆ្នាំ២០១៨ |
| ១២ | ការប្តឹងតវ៉ា ឬជំទាស់ និងការដោះស្រាយពាក្យបណ្តឹងតវ៉ាលើបញ្ជីបោះឆ្នោតដំបូងនៅក្រុមប្រឹក្សាធម្មនុញ្ញ | ថ្ងៃទី២៥ ខែមករា - ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ |
| ១៣ | ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតដោយ គ.ជ.ប | ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ |
| ១៤ | ការឃោសនាបោះឆ្នោត | ថ្ងៃទី១០ - ២៣ ខែកុម្ភៈ ឆ្នាំ២០១៨ |
| ១៥ | ថ្ងៃបោះឆ្នោត | ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ |
| ១៦ | ការរាប់សន្លឹកឆ្នោត ការបិទផ្សាយលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត | ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ (ក្រោយពេលបោះឆ្នោត) |
| ១៧ | ការប្តឹងជំទាស់ ឬតវ៉ា ទៅ គធ.ឧប (យ៉ាងយូរត្រឹមម៉ោង ១១:៣០នាទីព្រឹក) | ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ |
| ១៨ | ការដោះស្រាយពាក្យបណ្តឹង ការបូកសរុបលទ្ធផលនិងការបិទផ្សាយលទ្ធផល នៅ គធ.ឧប | ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ (ពេលល្ងាច) |
| ១៩ | ការប្តឹងតវ៉ាទៅ គ.ជ.ប លើការសម្រេចរបស់ គធ.ឧប រយៈពេល ២ថ្ងៃ | ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ) |
| ២០ | ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប រយៈពេល ២ថ្ងៃ | ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ) |
| ២១ | ការប្រកាសផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលភូមិភាគ ដោយ គ.ជ.ប (តាមករណីមាន ឬគ្មានបណ្តឹង) | ថ្ងៃទី២៧ ខែកុម្ភៈ - ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨ |
| ២២ | ការប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន | ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ) |
| ២៣ | ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង | ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ) |
| ២៤ | ការប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងបដិសេធពី គ.ជ.ប | ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ) |
| ២៥ | ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០-២០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង | ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ) |
| ២៦ | ការប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការប្រកាសផ្សាយបញ្ជីបេក្ខជនជាប់ឆ្នោត (តាមករណីគ្មាន ឬមានបណ្តឹង) | ថ្ងៃទី៣ ខែមីនា - ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨ |

បោះពុម្ព និងផ្សព្វផ្សាយ
ដោយ គ.ជ.ប
ឆ្នាំ ២០១៨

អាសយដ្ឋាន ៖ ទីស្តីការ គ.ជ.ប លេខ ២៧៨ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

E-mail: necinfo@forum.org.kh

គេហទំព័រ ៖ www.necelect.org.kh, www.voterlist.org.kh

Facebook: National Election Committee គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត